**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០៧ ផក

# ផែនការ

# ស្តីពី

# យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី២ រយៈពេល០៦ខែ (ចាប់ពីថ្ងៃទី ០១ ខែ កក្កដា ដល់ថ្ងៃទី ៣១ខែ ធ្នូ ឆ្នាំ ២០១៧)

យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនលើកទី១ រយៈពេល០៦ខែ ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៧ របស់រាជរដ្ឋាភិបាល ត្រូវបានចាត់តាំងអនុវត្តយ៉ាងសកម្មផុលផុស ដោយមានការចូលរួមយ៉ាងសស្រាក់សស្រាំពីគ្រប់ស្រទាប់ប្រជាពលរដ្ឋ មន្ត្រីរាជការនិងមហាជនក្នុងសង្គម ដែលបង្កើតបានជាចលនាជាតិក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយទទួលបានលទ្ធផលល្អប្រសើរ ព្រមទាំងមានការគាំទ្រនិងវាយតម្លៃជាវិជ្ជមាន ពីសំណាក់សាធារណៈមតិជាតិ-អន្តរជាតិ ចំពោះស្មារតីទទួលខុសត្រូវខ្ពស់របស់រាជរដ្ឋាភិបាលលើជោគវាសនាប្រទេសជាតិ និងប្រជាពលរដ្ឋ។

ជាក់ស្តែង បានលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋទូទៅមួយកំរិតថែមទៀត ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចាត់វិធានការរដ្ឋបាល ដើម្បីទប់ស្កាត់ការរីករាលដាលនៃការជួញដូរ ប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ព្រមទាំងបានបង្កើនប្រសិទ្ធភាពក្នុងការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ជាពិសេសបានបើកប្រតិបត្តិការយ៉ាងក្តៅគគុក បង្ក្រាបការជួញដូរ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់ចំនួន**៤.៣៣១ករណី** ឃាត់ខ្លួនជនសង្ស័យចំនួន **៩.៦៩៤នាក់** និងចាប់យកសារធាតុញៀនគ្រប់ប្រភេទសរុប **១១៩.៦៥៧ក្រាម** ព្រមទាំងមធ្យោបាយ សម្ភារៈ វត្ថុតាងមួយចំនួន។ ក្នុងនោះ បានបង្ក្រាបចាប់ខ្លួនមេក្លោង ជួញដូរគ្រឿងញៀនធំៗចំនួន **១៣ករណី** ដោយបានកាត់ផ្តាច់ខ្សែរយៈបណ្តាញ ធ្វើឲ្យចរន្តនៃការចរាចរ ជួញដូរគ្រឿងញៀនខុសច្បាប់ ថមថយសកម្មភាពគួរឲ្យកត់សម្គាល់។

លទ្ធផលខាងលើនេះ បានធ្វើឲ្យបទល្មើសព្រហ្មទណ្ឌមានការថយចុះ និងជះឥទ្ធិពលជាវិជ្ជមានដល់បរិយាកាសសន្តិសុខ សណ្តាប់ធ្នាប់សង្គមជាទូទៅ និងបានជួយកាត់បន្ថយទុក្ខលំបាក និងក្តីបារម្ភរបស់ពលរដ្ឋក្នុងមូលដ្ឋាន រួមចំណែកដល់ការអនុវត្តន៍កម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល។

ក៏ប៉ុន្តែអាស្រ័យដោយនិន្នាការនៃការផលិត ការចរាចរ និងការជួញដូរគ្រឿងញៀនខុសច្បាប់នៅក្នុងតំបន់ និងលើពិភពលោក នៅតែមានកំណើន និងនៅតែបន្តជះឥទ្ធិពលប្រកបដោយគ្រោះថ្នាក់ដល់កម្ពុជា រាជរដ្ឋាភិបាល

សម្រេចដាក់ចេញនូវផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់**លើកទី២** រយៈពេល០៦ខែ ដោយគិតចាប់ពីថ្ងៃទី ០១ ខែ កក្កដា រហូតដល់ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧ ដូចខាងក្រោម៖

## I. គោលគោលការណ៍រួម

- បន្តចាត់តាំងអនុវត្តឲ្យកាន់តែមានប្រសិទ្ធភាព នូវបទបញ្ជាលេខ **០១ ប.ប** ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន

- ចាត់តាំងអនុវត្តយុទ្ធនាការលើកទី២ ដោយផ្អែកតាមគោលការណ៍រួម និងវិធានការទាំង៥ នៃផែនការលេខ **០១ ផ.ក** ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៦ ដែលបានចាត់តាំងអនុវត្តក្នុងយុទ្ធនាការលើកទី១

- បន្តពង្រឹងយន្តការដែលមានស្រាប់ ក្នុងផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ **លើកទី១** ដើម្បីប្រើប្រាស់ជាយន្តការសម្រាប់អនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់**លើកទី២**។

## II. វិធានការ

បន្តជម្រុញការអនុវត្តវិធានការទាំង ៥ ដែលមានចែងក្នុងផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១ ឲ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត ទន្ទឹមនឹងនោះ ត្រូវប្រមូលផ្តុំយកចិត្តទុកដាក់លើការងារចម្បងៗ ជាអាទិភាពដូចតទៅ ៖

**១.** ត្រូវខិតខំធ្វើឲ្យប្រជាពលរដ្ឋទូទៅកាន់តែមានការយល់ដឹងថែមទៀត អំពីគ្រោះថ្នាក់ និងផលអវិជ្ជមានដែលកើតចេញពីគ្រឿងញៀន សំដៅកាត់បន្ថយបទល្មើសគ្រឿងញៀន ការពារសុខុមាលភាពសង្គម ដោយត្រូវយកចិត្តទុកដាក់ផ្តោតការអប់រំឲ្យចំគោលដៅ និងមុខសញ្ញាងាយរងគ្រោះ។

**២.** ជំរុញសកម្មភាពរៀបចំវេទិកាជួបជាមួយវិស័យឯកជន និងសប្បុរសជន ជាពិសេសម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មដែលងាយកើតមានបទល្មើសគ្រឿងញៀន និងសិល្បៈករ-សិល្បៈការិនី បណ្តាញព័ត៌មាន អ្នកដឹកនាំសាសនា ព្រមទាំងអង្គការ សង្គមស៊ីវិល ឲ្យបានគ្រប់រាជធានី-ខេត្ត រហូតដល់មូលដ្ឋាន សំដៅប្រមូលផ្តុំឲ្យមានការចូលរួម សហការគាំទ្រទាំងសកម្មភាពនិងមូលនិធិ ក្នុងចលនាជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**៣.** ពង្រឹងចំណាត់ការវិធានការរដ្ឋបាល និងការអនុវត្តន៍វិធានការច្បាប់ឲ្យបានហ្មឺងម៉ាត់ ចំពោះគោលដៅដែលងាយបង្កឬកើតមានការជួញដូរនិងប្រើប្រាស់គ្រឿងញៀន តាមរយៈការជំរុញឲ្យមានការកំណត់ភូមិសាស្ត្រ និងគោលដៅអាទិភាពជាក់លាក់ ព្រមទាំងមានកម្មវិធីការងារសម្រាប់កិច្ចការនេះច្បាស់លាស់ជាប្រចាំ។

**៤.** ជម្រុញការពិះរកនីតិវិធីក្នុងការចាត់ចែងវត្ថុតាង និងទ្រព្យសម្បត្តិនានា ដែលត្រូវបានរឹបអូស និងបង្កកពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនឲ្យបានឆាប់រហ័ស ដើម្បីប្រសិទ្ធភាពក្នុងសកម្មភាពប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**៥.** ជម្រុញការទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀន ជាពិសេសបន្តខិតខំទប់ស្កាត់ការនាំចូលពីក្រៅប្រទេស និងស្រាវជ្រាវបង្ក្រាបឲ្យបាននូវបណ្តាញខ្សែរយៈឧក្រិដ្ឋជនជួញដូរគ្រឿងញៀនធំៗ ព្រមជាមួយនឹងការយកចិត្តទុកដាក់ក្នុងការថែបំប៉ន និងលើកកម្ពស់សមត្ថភាពមន្ត្រីអនុវត្តច្បាប់ លើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ សំដៅធ្វើឲ្យប្រតិបត្តិការបង្ក្រាបគ្រឿងញៀនខុសច្បាប់ កាន់តែមានប្រសិទ្ធភាពខ្ពស់។

៦. ជម្រុញឲ្យបានសម្រេច ការកសាងមជ្ឈមណ្ឌលស្តារនីតិសម្បទា និងបណ្តុះបណ្តាលវិជ្ជាជីវៈថ្នាក់ជាតិ និងមណ្ឌលបណ្តោះអាសន្នសម្រាប់ព្យាបាល និងស្តារនីតិសម្បទាតាមរាជធានី-ខេត្ត ដែលមានអំណោយផល ស្របជាមួយនិងការលើកកម្ពស់សមត្ថភាព គុណភាព និងពង្រីកសេវាព្យាបាលដោយផ្អែកលើសហគមន៍។

III. **ការចាត់តាំងអនុវត្ត**

១. គណៈបញ្ជាការដឹកនាំយុទ្ធនាការលើកទី២នេះ គឺ៖

- **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ **ជាប្រធានយុទ្ធនាការ**

- **ឯកឧត្តម នាយឧត្តមសេនីយ៍ កែ គីមយ៉ាន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជា **អនុប្រធានយុទ្ធនាការ**

- លេខាធិការដ្ឋាន គណៈកម្មការចម្រុះទាំង៦ អនុគណៈកម្មការចម្រុះទាំង៣ និងគណៈកម្មាធិការត្រួតពិនិត្យ គ្រឿងញៀនរាជធានី-ខេត្តទាំង២៥ ដែលបានរៀបចំ និងដំណើរការនៅក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់**លើកទី១** ត្រូវបន្តដំណើរការ **ជាយន្តការសម្រាប់ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿង-ញៀនខុសច្បាប់លើកទី២** ។

២. ផ្អែកលើផែនការនេះ គណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី២ លេខាធិ-ការដ្ឋាន គណៈកម្មការចម្រុះទាំង៦ អនុគណៈកម្មការទាំង៣ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្តទាំង២៥ ត្រូវកសាងផែនការជាក់ស្តែងសម្រាប់ចូលរួមអនុវត្តតាមតួនាទី ភារកិច្ចរៀងៗខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

៣. ត្រូវមានវិធានការលើកសរសើរ ជូនរង្វាន់សមស្របដល់អង្គភាព និងបុគ្គលដែលមានស្នាដៃក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀន និងមានវិធានការអនុវត្តវិន័យហ្មឺងម៉ាត់ចំពោះមន្ត្រីដែលមានជាប់ពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។

ទទួលបានផែនការនេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងគណៈអភិបាលរាជធានី-ខេត្តទាំងអស់ ត្រូវចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធខ្ពស់៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៧

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**